# បទសម្ភាសន៍ជាមួយអ្នកស្រី ហេឡែន ចាវីស ប្រធានអង្គភាពជនរងគ្រោះ

*ដោយលោក ម៉ៃខល សាលីបា*

*ថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៩*

*ប្រែសម្រួលដោយ ទែន សុខស្រីនិត និង វ៉ាន់ថាន់ ពៅដារ៉ា*

*លោកស្រី ហេឡែន ចាវីស គឺជាប្រធានអង្គភាពជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ។ មុនពេលទទួលបានការតែងតាំងជាប្រធានអង្គភាពជនរងគ្រោះ លោកស្រីធ្លាប់ធ្វើជាប្រធានកិច្ចការសាធារណៈ ។ អ្នកស្រីធ្លាប់ធ្វើជាអ្នកពិគ្រោះយោបល់ផ្នែកឯកសារសម្រាប់កម្មវិធីស្រាវជ្រាវពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ដែលក្រោយមកឈានដល់ការបង្កើតមជ្ឈមណ្ឌលឯកសារកម្ពុជា ។ នៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៩ លោកស្រី ហេឡែន ចាវីស បានជួបនឹងមន្ត្រីដែលធ្វើការឲ្យគេហទំព័រឃ្លាំមើលសាលាក្តីខ្មែរក្រហមនៅកម្ពុជា ដែលហៅកាត់ថា ស៊ី.ធី.អ៊ឹម ដើម្បីពិភាក្សាអំពីការងាររបស់អង្គភាពជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។*

**ស៊ី.ធី.អ៊ឹម ៖** *ការិយាល័យកិច្ចការសាធារណៈ តែងតែគូសបញ្ជាក់ពីចំនួនអ្នកភូមិដ៏ច្រើនដែលបានមកតាមដានសវនាការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ ។ តើអង្គភាពជនរងគ្រោះមានតួនាទីអ្វីក្នុងការនាំប្រជាជនឲ្យមកចូលរួមតាមដានសវនាការរបស់តុលាការនេះ?*

**ចាវីស៖** *ខណៈពេលដែលថា វាជាការល្អក្នុងការបញ្ជាក់ជូនពីជោគជ័យបែបនេះ ផ្នែកកិច្ចការសាធារណៈរបស់តុលាការមានការទទួលខុសត្រូវយ៉ាងសំខាន់ ក្នុងការនាំអ្នកភូមិដ៏ច្រើនមកកាន់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ ។ យ៉ាងណាមិញ អង្គភាពជនរងគ្រោះបានសម្រួលដល់ការមកទស្សនារបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងករណីរបស់ ឌុច ដើម្បីតាមដាន និងចូលរួមក្នុងដំណើរការនីតិវិធីនៅក្នុងបន្ទប់សវនាការដោយផ្ទាល់ ។ យើងបានផ្តល់មធ្យោបាយធ្វើដំណើរពីភូមិរបស់គាត់មកកាន់ទីក្រុងភ្នំពេញ ហើយរៀបចំកន្លែងស្នាក់នៅជូនដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះ ប្រសិនបើអ្នកទាំងនោះត្រូវការ ។ រៀងរាល់ព្រឹក យើងបានរៀបចំរថយន្ត ដើម្បីជូនដំណើរដើមបណ្តឹងរដ្ឋបវេណី ចេញពីការិយាល័យអង្គភាពជនរងគ្រោះទៅកាន់ជាយក្រុងភ្នំពេញដែលជាកន្លែងដែលតុលាការតាំងទី ។ ក្រៅពីការសម្រួលដល់ការ*

ចូលរួមទស្សនាដូចបានរៀបរាប់ខាងលើនេះ ការងារភាគច្រើនរបស់អង្គភាពជនរងគ្រោះ ផ្តោតជាសំខាន់លើការប្រមូល និងសង្ខេបពាក្យបណ្តឹង និងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ។

**ស៊ី.ធី.អ៊ឹម :** តើអ្នកស្រីអាចពន្យល់ពីភាពខុសគ្នារវាងការដាក់ពាក្យបណ្តឹង និងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានដែរឬទេ?

**ចាវីស:** ពាក្យបណ្តឹង គ្រាន់តែជាការរៀបរាប់ពីឧក្រិដ្ឋកម្មដែលបុគ្គលម្នាក់ជឿជាក់ថាបានកើតមានឡើង ។ ពាក្យបណ្តឹងនេះត្រូវបានដាក់ជូនតុលាការ ហើយតុលាការធ្វើការសម្រេចថានឹងត្រូវបន្តកិច្ចតទៅទៀតឬក៏យ៉ាងណា ។ អ្នកប្តឹងផ្តល់ព័ត៌មានជូនតុលាការ ប៉ុន្តែមិនមានសិទ្ធិលើសពីនេះនៅក្នុងដំណើរការនីតិវិធីរបស់តុលាការឡើយ ។ អ្នកប្តឹងក៏អាចដាក់ពាក្យសុំតាំងខ្លួនធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីបាន ហើយប្រសិនបើតុលាការទទួលស្គាល់ គាត់នឹងទទួលបានសិទ្ធិចូលរួមទាំងអស់ ។

ប្រជាជនភាគច្រើនផ្តោតការយកចិត្តទុកដាក់លើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងអំឡុងពេលសវនាការ ដែលនៅទីនោះ ដើមបណ្តឹងរដ្ឋប្បវេណីនឹងចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌដោយធ្វើការគាំទ្រដល់អយ្យការ ។ មិនត្រឹមតែប៉ុណ្ណោះ ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិសំខាន់ៗខ្លះទៀតក្នុងអំឡុងពេលនៃដំណាក់កាលស៊ើបអង្កេត ។ សិទ្ធិទាំងនេះរួមបញ្ចូលទាំង សិទ្ធិជួបសម្ភាសន៍ និងចោទសួរសាក្សី សិទ្ធិរកទទួលនិងអានឯកសារក្នុងសំណុំរឿង និងសិទ្ធិទទួលបានអ្នកតំណាងជាមេធាវី ។ ដើមបណ្តឹងរដ្ឋប្បវេណីក៏អាចទទួលបានការការពារតាមនីតិវិធី នៅពេលដែលខ្លួនត្រូវបានចោទសួរ និងសិទ្ធិបន្ថែមមួយចំនួនទៀតក្នុងដំណើរការប្តឹងឧទ្ធរណ៍ ។

**ស៊ី.ធី.អ៊ឹម :** តើអង្គភាពជនរងគ្រោះ មានតួនាទីអ្វីខ្លះក្នុងការបង្ក្រងពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយតើជនរងគ្រោះមាននៅរស់រានមានជីវិត ឬក្រុមគ្រួសារជួបការលំបាកខ្លាំងអ្វីខ្លះក្នុងដំណើរការដាក់ពាក្យបណ្តឹង?

**ចារីស** ៖ អង្គភាពជនរងគ្រោះជួយប្រមែប្រមូល, ចាត់ដំណើរការ, ព្រមទាំងសង្ខេបពាក្យបណ្តឹងសុំតាំងខ្លួនជាដើមរដ្ឋប្បវេណី ។ មកដល់សព្វថ្ងៃនេះ អង្គការក្រៅរដ្ឋាភិបាលជាច្រើនក៏បានចូលរួមយ៉ាងសកម្មក្នុងការប្រមូលពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ។ ប៉ុន្តែដោយសារតែអង្គការភាគច្រើន ចាប់ផ្តើមបង្វែរចំណាប់អារម្មណ៍របស់ខ្លួនទៅលើវិស័យផ្សេងៗនោះ អង្គភាពជនរងគ្រោះនឹងបំពេញតួនាទីដ៏សំខាន់ក្នុងការប្រមូលពាក្យបណ្តឹងវិញម្តង ។ បន្ទាប់ពីប្រមូលបានពាក្យបណ្តឹង យើងនឹងធ្វើការរៀបចំ និងសង្ខេបខ្លឹមសារ ។ ជាពិសេសយើងធ្វើការជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេត ក្នុងការស្រង់យកធាតុផ្សំនៃបទឧក្រិដ្ឋដែលកំពុងត្រូវបានស៊ើបអង្កេតចេញពីពាក្យបណ្តឹងទាំងនោះ ។ ដំណើរការប្រមូល ចាត់ការបន្ត និងសង្ខេបពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឺជាកិច្ចការមួយយ៉ាងធំ ។ ពាក្យបណ្តឹងមួយចំនួនផ្ទុកទៅដោយឯកសារសំអាងរហូតដល់ទៅ ១០០ទំព័រឯណោះ ។ ព័ត៌មានក្នុងនោះភាគច្រើនពិបាកនឹងសង្ខេប ហើយពុំសូវមានភាពច្បាស់លាស់ទៀតផង ។ យើងអាចយល់ពីបញ្ហានេះបាន ពីព្រោះថា ឧក្រិដ្ឋកម្មដែលកើតឡើងបានកន្លងផុតអស់រយៈពេលជាង៣០ឆ្នាំទៅហើយ ។

**ស៊ី.ធី.អ៊ឹម** ៖ មានការពិភាក្សាជាច្រើន អំពីកំណែទម្រង់គំរូនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងពេលអនាគត់ ។ តើអង្គភាពជនរងគ្រោះគាំទ្រចំពោះលទ្ធផលដែលកើតចេញពីកិច្ចប្រជុំពេញអង្គលើកទី៦ លើបញ្ហានេះដែរឬទេ?

**ចារីស** ៖ ជាគោលការណ៍ យើងគាំទ្រចំពោះតម្រូវការចាំបាច់នូវគំរូនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានប្រសិទ្ធិភាពខ្ពស់ និងកិច្ចសហប្រតិបត្តិការល្អជាងនេះ ។ នេះគឺជាការពិតណាស់ដែលថា សំណុំរឿងបន្ទាប់នឹងមានលក្ខណៈស្មុគស្មាញកាន់តែខ្លាំងជាងមុន ហើយវិសាលភាពនៃឧក្រិដ្ឋកម្មនឹងមានទំហំកាន់តែធំឡើងៗ ។ ក្នុងសំណុំរឿងប្រឆាំងនឹង ឌុច ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ត្រូវបានប្រមូលជាក្រុមដោយគ្មានការគិតពីលក្ខណៈសម្បត្តិឬផលប្រយោជន៍ខុសប្លែកគ្នានោះទេ ។ ក្នុងសំណុំរឿងលេខ០០២ ដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវប្រមូលជាក្រុម ដោយផ្អែកលើប្រភេទនៃផលប្រយោជន៍ស្រដៀងៗគ្នា ។ ឧទាហរណ៍ដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវប្រមូលផ្តុំជាក្រុម ដោយផ្អែកលើឧក្រិដ្ឋកម្មជាក់លាក់ដែលបានកើតមានឡើង ឬជាតិពន្ធុជាក់លាក់ណាមួយដែលត្រូវបានដៅយក ។ ក្រុមទាំងនេះនឹង

ត្រូវបានតំណាងដោយសហមេធាវី ២រូប ដែលនឹងនិយាយក្នុង “សម្លេងតែមួយ” នៅក្នុងបន្ទប់សវនាការ ។ នេះមិនមែនចង់និយាយថា បទពិសោធន៍ដែលទាក់ទិននឹងដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿងប្រឆាំងនឹង ឌុច មិនទទួលបានជោគជ័យនោះទេ ។ ផ្ទុយទៅវិញដើមបណ្តឹងរដ្ឋប្បវេណីច្រើនជាង ២២នាក់ ត្រូវបានផ្តល់ឱកាសធ្វើសក្ខីកម្ម ហើយនេះជាតុលាការទីមួយក្នុងចំណោមតុលាការប្រភេទដូចគ្នា ដែលតំណាងឲ្យផលប្រយោជន៍របស់ជនរងគ្រោះក្នុងរបៀបដែលទូលំទូលាយបែបនេះ ។

**ស៊ី.ធី.អ៊ឹម :** តើមានកិច្ចសហការរវាងអង្គភាពជនរងគ្រោះនិងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងអំឡុងពេលនៃការធ្វើពហិការមិនចូលរួមសវនាការរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែរឬទេ? ប្រសិនបើគ្មានទេ តើអង្គភាពជនរងគ្រោះមានទស្សនៈយ៉ាងណាដែរចំពោះការធ្វើពហិការនេះ?

**ចារីស :** អង្គភាពជនរងគ្រោះមិនប្រកាន់ជំហរអ្វីទាំងអស់នៅក្នុងការធ្វើពហិការនេះ ។ មានភាពខុសគ្នារវាងតួនាទីរបស់អង្គភាពជនរងគ្រោះ និងមេធាវីរបស់ដើមបណ្តឹងរដ្ឋបវេណី ។ មេធាវីទទួលខុសត្រូវសម្រាប់ជួយដល់កូនក្តីរបស់ខ្លួន ចំណែកឯមុខនាទីរបស់យើងគឺ ជួយសម្រួលដល់ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងដំណើរការនីតិវិធីតែប៉ុណ្ណោះ ។ ជាការពិតដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិសម្តែងមតិរបស់ខ្លួនដោយខ្លួនឯងផ្ទាល់ ឬតាមរយៈមេធាវីរបស់ខ្លួន ក៏ប៉ុន្តែវាពិតជាមិនសមរម្យទេសម្រាប់ផ្នែកមួយរបស់តុលាការ ដូចជាអង្គភាពជនរងគ្រោះក្នុងការប្រកាន់ជំហរដែលផ្ទុយនឹងផ្នែកផ្សេងៗទៀតរបស់តុលាការនោះ ។